សហគមន៍មានសុវត្ថិភាព ៣

ធ្នូ ២០០៧

# ការជួយគាំទ្រដល់សាធារណជន

## ការបង្កើនការយល់ដឹងទៅលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់នៅក្នុងប្រទេសកម្ពុជា

### ពត៌មានសង្ខេប

ករណីសិក្សានេះរៀបរាប់អំពីយុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ដែលអនុវត្តនៅក្រោមកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ ដែលជាផ្នែកទី៤នៃកម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ ហើយដែលអនុវត្តដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) ដោយមានការជួយគាំទ្រពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) អនុវត្តនៅក្នុងខេត្តគោលដៅចំនួនពីររបស់ប្រទេសកម្ពុជា។ បទពិសោធន៍ដែលទទួលបានពីការអនុវត្តនកម្មវិធីនេះនឹងផ្តល់ជាអត្ថប្រយោជន៍ច្រើនដល់បុគ្គលនិងអង្គការទាំងឡាយណាដែលមានបំណងរៀបចំនូវយុទ្ធនាការបង្កើនការយល់ដឹងបែបនេះ។ យុទ្ធនាការនេះលើកឡើងនូវឧទាហរណ៍ល្អៗជាច្រើននៃការអនុវត្តនដ៏សមស្រប និងបង្ហាញពីការប្រើប្រាស់នីតិវិធីដ៏សមរម្យមួយទៅលើការបង្កើនចំនេះដឹងនៃការកាត់បន្ថយគ្រោះទឹកជំនន់។ នៅក្នុងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះទឹកជំនន់នេះ សកម្មភាពមួយត្រូវបានសំរបសំរួលដោយដៃគូអនុវត្តន៏ពាក់ព័ន្ធនៅតាមមូលដ្ឋានត្រូវបានផ្តល់ឱកាស ដើម្បីរំលឹកឡើងវិញនូវឯកសារពត៌មានដែលមានស្រាប់ស្តីពីបញ្ហាគ្រោះទឹកជំនន់ហើយប្រើប្រាស់ពត៌មានទាំងនេះ ដើម្បីផ្សព្វផ្សាយទៅដល់សាធារណៈជននៅតាមមូលដ្ឋានរបស់ពួកគេ។ លទ្ធផលទាំងនេះ គឺជាការអនុវត្តន៏នូវគំនិតដ៏ល្អៗហើយក្រៅពីយុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះទឹកជំនន់នេះវាក៏ជាកត្តាមួយកំណត់នូវចំនួនប្រជាជនដែលងាយរងគ្រោះដោយទឹកជំនន់ផងដែរគឺស្ត្រី និង កុមារ។

### ខ្លឹមសាររឿង

- យុទ្ធសាស្ត្រនៃកម្មវិធីពង្រឹងការគ្រប់គ្រងភាព អាសន្នគ្រោះទឹកជំនន់(FEMS) សំរាប់សកម្មភាព បង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ ២
- បណ្តាញបញ្ជូនពត៌មាន ៤
- បទពិសោធន៏មេរៀនដែលទទួលបានពីការអនុវត្តន៏ ៧
- ជំហានអនុវត្តន៏បន្ទាប់ ៧



ប្រភពរូបថត: វេទិការទឹកជំនន់ទន្លេមេគង្គប្រចាំឆ្នាំ លើកទី៦, របាយការណ៏កម្ពុជា ឆ្នាំ ២០០៧



ទឹកជំនន់រហ័សនៅក្នុងខេត្តព្រះវិហារ ។ ការយល់ដឹងរបស់សហគមន៏អំពីទឹកជំនន់ចាំបាច់ត្រូវតែលើកកំពស់ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់ទឹកជំនន់ដល់ប្រជាជនរស់នៅតាមតំបន់ទឹកជំនន់ ។ ( ប្រភព: វេទិការទឹកជំនន់ទន្លេមេគង្គប្រចាំឆ្នាំ លើកទី៦, របាយការណ៏កម្ពុជា ឆ្នាំ ២០០៧)

*នៅក្នុងកិច្ចការងារមួយចំនួនលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ការរៀបចំ និងការអនុវត្តន៏យុទ្ធនាការអប់រំ និងបង្កើនការយល់ដឹងដល់សាធារណៈជន គឺជាសកម្មភាពដ៏សំខាន់មួយដែលបានអនុវត្តន៏ ។ យុទ្ធនាការនេះ ជាមូលដ្ឋានគ្រឹះមួយ ដែលធ្វើអោយសកម្មភាពកាត់បន្ថយគ្រោះទឹកជំនន់ អាចអនុវត្តន៏ទៅបាន កាន់តែមានប្រសិទ្ធភាព ។ បុគ្គលិកមន្ត្រី នៅមូលដ្ឋាននិងប្រជាពលរដ្ឋនៅតាមសហគមន៏ ដែលជាមុខសញ្ញាគំរាមកំហែងពីគ្រោះទឹកជំនន់ត្រូវបានបណ្តុះបណ្តាលអោយយល់ដឹងពីវិធានការកាត់បន្ថយ និង ត្រៀមបង្ការទៅនឹងគ្រោះទឹកជំនន់នេះដែលជាសកម្មភាពអនុវត្តន៏ដ៏ងាយមួយក្នុងការកាត់បន្ថយឥទ្ធិពលដ៏អាក្រក់នៃគ្រោះទឹកជំនន់បើគ្មានទស្សនវិស័យពីសហគមន៏និងអាជ្ញាធរមូលដ្ឋានទេវានឹងមានការពិបាកក្នុងការទទួលបានការចូលរួមពីពួកគេនៅក្នុងកម្មវិធីនិងសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់នេះ ។*

### សេចក្តីផ្តើម

កាលពីខែ កញ្ញា ឆ្នាំ ២០០៤ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) បានចាប់ផ្តើមអនុវត្តន៏សកម្មភាពរបស់ភ្នាក់ងារសហប្រតិបត្តិការផ្តល់បច្ចេកទេសអន្តរជាតិអាឡឺម៉ង់ (GTZ) ដែលឧបត្ថម្ភទៅលើកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់(FEMS) ដោយមានការជួយគាំទ្រពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី(ADPC) ដែលអនុវត្តន៏នៅក្នុងខេត្តគោលដៅចំនួន ២ គឺខេត្តព្រៃវែង និង ខេត្តកណ្តាល ។ កម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ជាផ្នែកមួយក្នុងចំនោមផ្នែកទាំង៥នៃកម្មវិធីដ៏យូរអង្វែងរបស់គណៈកម្មការទន្លេមេគង្គ (MRC) ដែលជាកម្មវិធីគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) ហើយកម្មវិធីនេះមានទិសដៅការពារ និងកាត់បន្ថយផលប៉ះពាល់អាក្រក់ ដែលបណ្តាលមកពីទឹកជំនន់ទៅលើជីវភាពរបស់ប្រជាពលរដ្ឋហើយ ថែរក្សាបរិស្ថាននៃទឹកជំនន់អោយនៅគង់វង្ស ។




លោក ហ៊ុល ចំរើន ជនបង្គោល នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង បានមានប្រសាសន៍ថា: "សកម្មភាពបង្កើនការយល់ដឹងស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាមិនមែនជារឿងធម្មតាសំរាប់យើងនោះទេ ដែលបានជួបប្រទះនូវ ទឹកជំនន់រយៈពេលប្រាំមួយខែ ដែលពេលនោះទឹកជំនន់ឡើងរហូតដល់ទៅ ១ ម៉ែត្រ ក្នុងរយៈពេលតែ ២៤ ម៉ោង " ។

ខេត្តចំនួនពីរ គឺខេត្តព្រៃវែង និងខេត្តកណ្តាល ត្រូវបានជ្រើសរើសជាខេត្តគោលដៅ ដោយសារខេត្តទាំងពីរនេះជាខេត្ត ដែលងាយរងផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់ដងទន្លេមេគង្គជាងខេត្តដទៃទៀត។ ទឹកជំនន់ធំកាលពីឆ្នាំ២០០០ -២០០១ ស្រុក និងឃុំជាង ៩០% របស់ខេត្តទាំងពីរត្រូវបានរងការប៉ះពាល់យ៉ាងខ្លាំង។ ការប៉ះពាល់នេះបានជះឥទ្ធិពលដល់ប្រជាជនចំនួន ៣០% នៃប្រជាជនសរុបក្នុងខេត្តកណ្តាល និង ប៉ះពាល់ដល់ប្រជាជនចំនួន ៦១% នៃប្រជាជនសរុបក្នុងខេត្តព្រៃវែង។ នៅក្នុងខេត្តព្រៃវែង ទោះបីជានៅក្នុងឆ្នាំណាដែលមានទឹកជំនន់ជនធម្មតាក្តីក៏វាមានផលប៉ះពាល់រហូតដល់រយៈពេល ៦ ខែដែរ។

ដូច្នេះយុទ្ធនាការបង្កើនការយល់ដឹងស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ត្រូវបានអនុវត្តដើម្បីជួយគាំទ្រ និង បំពេញទៅតាមតំរូវការនៃទិសដៅទាំងអស់របស់កម្មវិធីពង្រឹងការគ្រប់គ្រងភាអាសន្នគ្រោះទឹកជំនន់ (FEMS)។ នៅក្នុងយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈនេះ ដៃគូអនុវត្តន៍សំខាន់ៗលើការគ្រប់គ្រងគ្រោះមហន្តរាយទឹកជំនន់នៅក្នុងខេត្តជាគោលដៅទាំងអស់បានរួបរួមគ្នាដើម្បីរៀបចំ និង អនុវត្តន៍យុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់នៅក្នុងស្រុកគោលដៅទាំងបួន( ដែលមានពីរស្រុកនៅក្នុងខេត្តគោលដៅនីមួយៗ) ។

នៅចុងបញ្ចប់នៃជំហានទីមួយរបស់គំរោង នៅក្នុងខែធ្នូ ឆ្នាំ ២០០៧, អាជ្ញាធរមូលដ្ឋានគ្រប់កំរិតតាំងពីថ្នាក់ខេត្ត រហូតដល់ថ្នាក់ឃុំបានរៀបចំផ្សព្វផ្សាយយុទ្ធនាការបង្កើនការយល់ដឹងស្តីពីទឹកជំនន់ជាច្រើនវគ្គ។ កិច្ចការនេះចាត់ទុកថា ជាបទពិសោធន៍មួយដ៏ល្អពិសេសសំរាប់មន្ត្រីនៅមូលដ្ឋានដែលគាត់មិនដែលបានរៀបចំយុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់នេះទេកាលពីមុននោះ។

លោក ពុទ្ធ សារ៉ាត អនុប្រធាន មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តព្រៃវែង បានមានប្រសាសន៍ថា : " នេះជាលើកទីមួយដែលយើង បានចូលរួមនៅក្នុងយុទ្ធនាការបង្កើនការយល់ដឹងនេះ ដែលគាំទ្រដោយ កម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្ន គ្រោះទឹកជំនន់ (FEMS)ហើយលទ្ធផល នៃបទពិសោធន៍នេះមានប្រយោជន៍យ៉ាងធំធេង... យើងជឿជាក់ថានឹងរៀបចំយុទ្ធនាការនេះនៅពេលខាងមុខទៀត ។"

## ១‐យុទ្ធសាស្ត្រនៃកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) សំរាប់សកម្មភាពបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់

យុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ ដែលរៀបចំនេះ បានបែងចែកជាពីរក្រុម គឺមួយក្រុមផ្សព្វផ្សាយដល់សាធារណៈជនទូទៅហើយមួយក្រុមទៀតផ្សព្វផ្សាយដល់ក្រុមជនដែលងាយរងគ្រោះដោយសារទឹកជំនន់ជាងគេនៅក្នុងសហគមន៍នោះគឺកុមារនិង ស្ត្រីជាមេគ្រួសារ (WHHs)។ យុទ្ធសាស្ត្រដែលប្រើនៅក្នុងការអនុវត្តន៍នៃយុទ្ធនាការនេះ រួមមានដូចជា នីតិវិធីដោយមានការសហការចូលរួម, ការប្រើប្រាស់ឯកសារដែលមានស្រាប់ដោយបានកែសំរួលទៅតាមបរិបទមូលដ្ឋាន, ការកសាងសមត្ថភាពដល់សហគមន៍សំរាប់អនុវត្តនយុទ្ធនាការផ្សព្វផ្សាយបន្តនៅពេលអនាគត និង ការចែករំលែកចំណេះដឹង។

### ១.១-នីតិវិធីដោយមានការសហការ ចូលរួម

កត្តាដ៏ចំបងមួយដែលធ្វើអោយយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈនេះទទួលបានជោគជ័យនោះគឺដោយសារមានការចូលរួមនិងការសហការពីជនសកម្មដែលមានតួនាទីគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ខេត្ត។ ដៃគូអនុវត្តន៍ទាំងអស់តាំងពីថ្នាក់ខេត្ត រហូតដល់ជនបង្គោលតាមសហគមន៍ក៏បានចូលរួមពាក់ព័ន្ធផងដែរនៅក្នុងយុទ្ធនាការផ្សព្វផ្សាយនេះ។ ជាពិសេសជាងនេះទៅទៀតយុទ្ធនាការនេះគឺជាកិច្ចការចូលរួមរបស់មន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយតាមមូលដ្ឋានដែលមានដូចជាគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ស្រុក និងឃុំ, ជនបង្គោលនីដែលជាក្រុមប្រឹក្សាឃុំ,នាយកសាលា, គ្រូបង្រៀន, មន្ទីរពាក់ព័ន្ធដទៃទៀតនៅក្នុងខេត្តដូចជាមន្ទីរអប់រំយុវជននិងកីឡា, មន្ទីរកិច្ចការនារី, មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងមន្ទីរព័ត៌មាន, និង មានអង្គការក្រៅរដ្ឋាភិបាលនៅក្នុងស្រុក ពីរទៀតគឺ អង្គការស្រែខ្មែរ និង អង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា(PCC) ក៏បានចូលរួមក្នុងយុទ្ធនាការផ្សព្វផ្សាយនេះផងដែរ។



ការចូលរួមពីមន្ទីរពាក់ព័ន្ធក្នុងខេត្តលើការអនុវត្តន៍នូវយុទ្ធនាការផ្សព្វផ្សាយនេះបានធ្វើអោយមានភាពម្ចាស់ការដ៏ខ្លាំងមួយ ដែលវាមានសារៈសំខាន់ណាស់ សំរាប់សកម្មភាពបង្កើនការយល់ដឹងដែលនឹងត្រូវបន្តផ្សព្វផ្សាយទៅដល់សហគមន៍ដទៃទៀតនៅក្នុងខេត្ត។ ដោយមាននូវយុទ្ធសាស្រ្តដ៏ច្រើនបែបនេះនៃកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ទើបមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) បានសំរេចជ្រើសរើសយកមន្រ្តីនៅថ្នាក់ខេត្តធ្វើជាអ្នកដឹកនាំសកម្មភាពយុទ្ធនាការផ្សព្វផ្សាយទាំងមូលនេះ។ អង្គការ ADPC បានផ្តល់ជាជំនួយបច្ចេកទេសគាំទ្រលើដំណើរការយុទ្ធនាការទាំងមូលនេះដោយផ្អែកលើបទពិសោធន៍របស់ខ្លួនផ្ទាល់ និង ឯកសារវិធីសាស្រ្តដែលបានសាកល្បងកន្លងមក ដែលប្រើប្រាស់ដោយអង្គការក្រៅរដ្ឋាភិបាលអនុវត្តន៍ទៅលើសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងប្រទេសកម្ពុជា និងនៅតាមបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ជាដើម។

## ១.២-ការកែសំរួលទៅតាមលក្ខ័ណ្ឌនៅតាមមូលដ្ឋាន

កត្តាដ៏សំខាន់មួយទៀតនៅក្នុងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈនេះ គឺការកែសំរួលឯកសារ និង ពត៌មានលើវិធានការការពារគ្រោះទឹកជំនន់ អោយសមស្របទៅនឹងប្រពៃណីនិងវប្បធម៌នៃការរស់នៅរបស់ពលរដ្ឋនៅមូលដ្ឋាន។ ការកែសំរួលនេះគឺធ្វើឡើង ដោយមានកិច្ចសហការប្រកបដោយជោគជ័យជាមួយអង្គការក្រៅរដ្ឋាភិបាលនៅក្នុងតំបន់គោលដៅ ដោយផ្តោតសំខាន់លើការចែករំលែកឯកសារពត៌មាន, ការបញ្ជូនពត៌មាន និងឯកសារអប់រំនានា លើវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់។ ការកែសំរួលនេះធ្វើឡើងតាមរយៈការរៀបចំ និងការប្រើប្រាស់ឯកសារបង្កើនការយល់ដឹងជាសាធារណៈ ដោយផ្អែកលើបទពិសោធន៍ និងចំណេះដឹងជាច្រើនរបស់អង្គភាពពាក់ព័ន្ធសំខាន់ៗនៅក្នុងខេត្ត ដែលធ្វើសកម្មភាពលើការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ដែលមានអង្គការក្រៅរដ្ឋាភិបាល,សាលារៀន និងមន្ទីរពាក់ព័ន្ធដទៃទៀតជាដើម។

ធនធាននិងពត៌មានលើការងារបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់បានចែករំលែកពីអង្គការថែរក្សាអន្តរជាតិ (CARE) និងអង្គការអុកស្វាមអង់គ្លេស (Oxfam-GB) នៅក្នុងប្រទេសកម្ពុជា។ អង្គការ CARE បានចែករំលែកនូវឯកសារមេរៀនស្តីពីការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ដែលបានបង្កើតឡើងដោយកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់កាលពីមុនរបស់អង្គការនេះ។ ចំណែកអង្គការ Oxfam GB វិញបានផ្តល់ជាសៀវភៅស្តីពីការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ និងខ្សែវីដេអូមួយដែលមានចំនងជើងថា "**ការរស់នៅជាមួយទឹកជំនន់**" ដែលធ្វើការកែសំរួល និងបកប្រែទៅជាភាសាខ្មែរហើយ ក៏បានប្រើប្រាស់នៅក្នុងសកម្មភាពអនុវត្តគំរោងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយតាមសហគមន៍ (CBDRR) នៅតាមកន្លែងជាច្រើន នៅក្នុងប្រទេសកម្ពុជា។ សៀវភៅដែលមានស្រាប់ ស្តីពី "**បញ្ហាសុខភាពនៅពេលទឹកជំនន់**" ដែលចងក្រងដោយក្រសួងសុខាភិបាល (MoH) ត្រូវបានផលិតសារជាថ្មីម្តងទៀត ហើយធ្វើការផ្សាព្វផ្សាយផងដែរ។ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (RUFA) ជាអ្នករៀបចំតាក់តែងសាច់រឿងស្តីពី "**ការរស់នៅជាមួយទឹកជំនន់**" ដែលបានប្រើប្រាស់សំរាប់ការសំដែងម្តងៗនៅលើឆាកនៅតាមសហគមន៍។

## ១.៣-ការបង្កើនប្រសិទ្ធភាពនៃការអនុវត្តន៍

កម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់(FEMS) ទាំងមូល ផ្តោតទៅលើការកសាងសមត្ថភាព ហើយកិច្ចប្រឹងប្រែងអនុវត្តន៍ក្នុងការផ្ទេរចំណេះដឹង និង ជំនាញអោយទៅអាជ្ញាធរមូលដ្ឋានគ្រប់ក៏រិតក៏បានប្រើប្រាស់នៅក្នុងការរៀបចំនិងអនុវត្តន៍យុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ផងដែរ។ ការជ្រើសរើសនីតិវិធីនេះ គឺចាត់ទុកថាមានសារៈសំខាន់ណាស់ ព្រោះយុទ្ធនាការបង្កើនការយល់ដឹងនេះក៏ដូចជាផ្នែកដទៃទៀតទាំងអស់របស់គំរោងកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) គឺធ្វើឡើងដើម្បីអនុវត្តន៍តែនៅក្នុងតំបន់ និងសហគមន៍គោលដៅតែប៉ុណ្ណោះ។ យុទ្ធនាការបន្តបន្ទាប់ទៀត នឹងធ្វើឡើង និងទ្រទ្រង់ថវិកា ដោយអង្គភាពមូលដ្ឋានរបស់ពួកគេផ្ទាល់។ ដើម្បីសំរេចបានគោលដៅនេះ អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកចំនួនពីរ ត្រូវបានកំនត់ និង ជ្រើសរើសយក អោយចូលរួមអនុវត្តន៍គំរោងនេះ ដែលអង្គការទាំងពីរនេះមានដូចជា អង្គការស្រែខ្មែរ (SK) និងអង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា (PCC)។ អង្គការស្រែខ្មែរ បានផ្តល់ជំនួយបច្ចេកទេសគាំទ្រដល់អាជ្ញាធរមូលដ្ឋានតាមរយៈការជួយសំរបសំរួលក្នុងវគ្គបណ្តុះបណ្តាល លើការគ្រប់គ្រងគ្រោះទឹកជំនន់តាមមូលដ្ឋានសហគមន៍(CBFM) ទៅដល់សមាជិកក្រុមប្រឹក្សាឃុំ និងដល់មន្រ្តីកម្មវិធីគាំទ្រកិច្ចអភិវឌ្ឍន៍បែបប្រជាធិបតេយ្យតាមរយៈ វិមជ្ឈការ និងវិសហមជ្ឈការ (PSDD) តាមរយៈការធ្វើបទបង្ហាញស្តីពីការគ្រប់គ្រងគ្រោះទឹកជំនន់នេះ និងតាមរយៈវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀននៅក្នុងសាលាគោលដៅចំនួនពីរ។

ការផ្សព្វផ្សាយការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ដល់សិស្សសាលាគ្រូបង្រៀននេះត្រូវបានផ្តល់តាមរយៈវិធីសាស្រ្តជាច្រើន ដូចជាតាមរយៈកិច្ចតែងការបង្រៀននិងតាមរយៈសំភារៈដូចជាផ្ទាំងរូបភាព និងពតិមានផ្សេងៗ ស្តីពីទឹកជំនន់ដើម្បីបង្រៀនពីការការពារគ្រោះទឹកជំនន់ដល់សិស្សសាលា។ ការផ្សព្វផ្សាយនេះ បានធ្វើអោយមានការរីកសាយដ៏ទូលំទូលាយនៅក្នុងសាលាទាំងនោះ ដែលវានឹងអាចបន្តផ្សព្វផ្សាយទៅដល់សាលាដទៃទៀតនៅពេលអនាគត។

ចំណែកអង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា (PCC) ក៏បានប្រមូល និង បង្រៀនទៅដល់ជនបង្គោលនារី ដែលជាក្រុមប្រឹក្សា ចំនួន ៨៩នាក់ ដែលមកពីគ្រប់ឃុំនៅក្នុងស្រុកគោលដៅ ហើយជនបង្គោលថ្នាក់ភូមិក៏ត្រូវបានកំនត់អោយចូលរួមនៅក្នុងវគ្គផ្សព្វផ្សាយនេះផងដែរ។ ឃុំនីមួយៗបានជួយនៅក្នុងការរៀបចំផែនការសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ សំរាប់ការផ្សព្វផ្សាយបន្តពីចំណេះដឹងគ្រោះភ័យនៃគ្រោះទឹកជំនន់នេះ។

## ១.៤-ការចែករំលែកបទពិសោធន៍

សន្និសិទ្ធ និង សិក្ខាសាលាបណ្តុះបណ្តាល គឺជាសកម្មភាពដ៏សំខាន់សំរាប់ការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ដោយវាបានផ្តល់អត្ថប្រយោជន៍ដ៏ច្រើនដូចជាបទពិសោធន៍, វិធីសាស្រ្ត និងសំភារៈជាច្រើន សំរាប់យុទ្ធនាការបង្កើនការយល់ដឹងពីគ្រោះភ័យ

លោក ជឹម ជឿន គ្រូបង្រៀន នៅសាលាបឋមសិក្សាវាលរបងលើ បានមានប្រសាសន៍ថា : " នៅក្នុងសាលានេះ រូបខ្ញុំ គឺជាគ្រូបច្ចេកទេសដែលទទួលបន្ទុកលើការរៀបចំកម្មវិធីសិក្សា ហើយគ្រូចំនួនប្រាំមួយនាក់ ពួកគាត់ បាន បង្រៀនពីវិធានការការពារគ្រោះទឹកជំនន់ទៅដល់សិស្ស ហើយជាលទ្ធផលពេលនេះមេរៀនស្តីពីគ្រោះទឹកជំនន់កំពុងតែបង្រៀនទៅដល់សិស្សចំនួន ២៦៤ នាក់ ដែលជាសិស្សបឋមសិក្សា ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៦ ។"

នៃគ្រោះទឹកជំនន់ ដែលទាំងនេះបានផ្ទេរនិងចែករំលែកអោយទៅដល់តំបន់ និងសហគមន៍ជាច្រើនទៀត ដែលនៅក្រៅតំបន់គោលដៅ។ មន្ត្រីនៅតាមមូលដ្ឋាន អាចបង្កើនចំនេះដឹង និងជំនាញ របស់ពួកគេ ដោយការចូលរួមនៅក្នុង សិក្ខាសាលានិងវគ្គបណ្តុះបណ្តាលជាច្រើនស្តីពីទឹកជំនន់នេះ។ ម្យ៉ាងវិញទៀតការចូលរួមរបស់ពួកគេនៅក្នុងការអនុវត្តន៍និងសិក្ខាសាលាចែករំលែកបទពិសោធន៍ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ បានធ្វើអោយពួកគេអាចពិភាក្សាបង្ហាញបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ និងទាញយកចំណេះដឹង និងបទពិសោធន៍ពីសហគមន៍ផ្សេងៗទៀត ទាំងនៅក្នុងប្រទេសនិងក្រៅប្រទេសដទៃទៀតផងដែរ។



*ផ្ទាំងរូបភាពរបស់ ADPC នេះជំរុញអោយសហគមន៍ចេះត្រៀមបង្ការដោយខ្លួនឯងមុនពេលទឹកជំនន់មកដល់ ហើយផ្តល់នូវដំបូន្មាននូវអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនគួរធ្វើ ក្នុងកំឡុងពេល និងបន្ទាប់ពីទឹកជំនន់*

សិក្ខាសាលាដែលបានចូលរួមដោយអាជ្ញាធរមូលដ្ឋាននៃថ្នាក់ខេត្ត ក្នុងកំឡុងពេល នៃកម្មវិធីនេះ មានសិក្ខាសាលាចំនួនពីរគឺ "សិក្ខាសាលាចែករំលែកចំនេះដឹង និង បទពិសោធន៍ថ្នាក់ជាតិ" និងសិក្ខាសាលាថ្នាក់តំបន់ស្តីពី "នីតិវិធីថ្មីលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់នៅក្នុងអាងទន្លេមេគង្គ" ដែលបានរៀបចំឡើងនៅក្នុងប្រទេសថៃ។ នៅក្នុងការបង្ហាញពីឆន្ទៈ និងការគាំទ្រទៅលើកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ខេត្តព្រៃវែង បានធ្វើជាម្ចាស់ផ្ទះលើសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការចែករំលែកមេរៀនបទពិសោធន៍នៅក្នុងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់។



*ក្តារខៀនពតិមានត្រូវបានដំឡើងនៅក្នុងខេត្តព្រៃវែងផ្តល់ពតិមានអោយសហគមន៍អំពីលក្ខណៈរបស់ទឹកជំនន់ ដែលប៉ះពាល់ទៅដល់ប្រជាជន។ ក្តារខៀនពតិមាននេះក៏ផ្តល់ដំបូន្មានផងដែរអំពីអ្វីដែលសហគមន៍គួរតែធ្វើដើម្បីត្រៀមបង្ការទឹកជំនន់ និង របៀបរស់នៅជាមួយទឹកជំនន់។*

## ២_បណ្តាញបញ្ជូនពត៌មាន

ការអនុវត្តន៍សកម្មភាពយុទ្ធនាការយល់ដឹងជាសាធារណៈនេះ ធ្វើឡើងតាមរយៈការផ្សព្វផ្សាយសារស្តីពីវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ដែលមានដូចជា ឯកសារបោះពុម្ព, ខ្សែវីដេអូ និងការសំដែងសិល្បៈនៅតាមសហគមន៍និងក្រុមដែលបានកំនត់ថាមានភាពងាយរងគ្រោះជាងគេបានប្រើប្រាស់បណ្តាញបញ្ជូនពតិមានដោយផ្ទាល់ រួមមានតាមរយៈក្រុមពិភាក្សា និង ក្រុមផ្សព្វផ្សាយនៅតាមសាលា។ លើសពីនេះទៅទៀតសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលជាច្រើនដែលបានរៀបចំនៅក្នុងគំរោងកម្មវិធីគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) នេះ ក៏ជាទឹកន្លែងសំរាប់បង្កើនការយល់ដឹងនេះផងដែរ ហើយក៏ចាត់ទុកជាប្រព័ន្ធផ្សព្វផ្សាយមួយនៃការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់។

### ២.១-ការរៀបចំយុទ្ធនាការយល់ដឹងជាច្រើន

- ***ឯកសារ ពតិមាន, អប់រំ និងឯកសារបញ្ជូនពតិមាន (IEC)***

ឯកសារពតិមាន និងឯកសារអប់រំ ដែលបោះពុម្ពធ្វើឡើងក្នុងទំរង់ជាលក្ខណៈមូលដ្ឋានគ្រឹះនិងសាមញ្ញបំផុតសំរាប់ជា ឯកសារយល់ដឹងជាសាធារណៈ។ ឯកសារទាំងនោះត្រូវបានប្រើប្រាស់ក្នុងយុទ្ធនាការយល់ដឹងពីគ្រោះទឹកជំនន់រួមមានកូនសៀវភៅដែលសំបូរទៅដោយពតិមានអប់រំល្អៗ ពីគ្រោះទឹកជំនន់និងផ្ទាំងរូបភាពធំៗ។ កូនសៀវភៅស្តីពីទឹកជំនន់បានរៀបចំដោយផ្អែកតាមសៀវភៅចាស់ដែលបានប្រើប្រាស់ដោយអង្គការ ADPC នៅក្នុងកម្មវិធីទឹកជំនន់កាលពីឆ្នាំ២០០២។

ការត្រួតពិនិត្យកែតំរូវជាមួយនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) និងមន្ត្រីថ្នាក់ខេត្ត ជាលទ្ធផលបានធ្វើការបោះពុម្ព និងបែងចែកចំនួន ៣.៥០០ច្បាប់។ សៀវភៅនេះ បានប្រើប្រាស់ក្នុងទំរង់ធ្វើជាឯកសារពតិមានសំរាប់ផ្តល់នៅក្នុងវគ្គបណ្តុះបណ្តាល ដែលរៀបចំសំរាប់សមាជិកក្រុមប្រឹក្សាខេត្ត, ស្រុកនិងឃុំ,ជនបង្គោលនារី និងគ្រូបង្រៀននៅតាមមូលដ្ឋាន ។

កូនសៀវភៅទឹកជំនន់នេះ អធិប្បាយអំពីស្ថានភាពទឹកជំនន់នៅក្នុងប្រទេសកម្ពុជា, និយមន័យងាយយល់នៃវាក្យស័ព្ទទឹកជំនន់,វិធានការត្រៀមបង្ការគ្រោះទឹកជំនន់ ដែលរួមមានការឆ្លើយតបទៅនឹងការប្រកាសអាសន្នគ្រោះទឹកជំនន់, ផលប៉ះពាល់សំខាន់ៗ និង គ្រោះថ្នាក់ពីទឹកជំនន់, ដំបូន្មានការពារខ្លួនពេលទឹកជំនន់ និងវិធានការជាច្រើនទៀតសំរាប់កាត់បន្ថយ និងការពារគ្រោះទឹកជំនន់ ដែលប្រជាពលរដ្ឋអាចធ្វើបាន។

ផ្ទាំងរូបភាពធំៗ ដែលមានពតិមានងាយអាននិងងាយយល់លើវិធានការកាត់បន្ថយនិងត្រៀមបង្ការគ្រោះទឹកជំនន់ ត្រូវបានផលិត និងដាក់បង្ហាញនៅតាមទីសាធារណៈជាច្រើន។ ផ្ទាំងរូបភាពនេះមានបីប្រភេទ ដែលបង្ហាញ នូវវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ នៅមុនពេល, អំឡុងពេល និងក្រោយពេលនៃទឹកជំនន់។ ផ្ទាំងរូបភាពទីទីពីរ ត្រូវបានរៀបចំយ៉ាងពិសេសផ្តោតលើការយល់ដឹងពីគ្រោះទឹកជំនន់សំរាប់សិស្សសាលា។ ផ្ទាំងរូបភាពទាំងនេះផ្តល់នូវការពិពណ៌នាដ៏សំខាន់ៗលើវិធានការការពារសំរាប់សិស្សសាលា ហើយផ្ទាំងរូបភាពនេះត្រូវបានកែសំរួលចេញពីផ្ទាំងរូបភាពនៅតាមសាលាដែលបានផលិតនិងប្រើប្រាស់ដោយអង្គការសម្ព័ន្ធភាពសង្គ្រោះកុមារ ក្នុងប្រទេសវៀតណាម។

ខ្សែវីដេអូដែលមានចំណងជើងថា:"ការរស់នៅជាមួយទឹកជំនន់" ត្រូវបានផលិតដោយអង្គការអុកស្វាមអង់គ្លេស(OxfamGB) នៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០០៥ ហើយបានប្រើប្រាស់យ៉ាងទូលំទូលាយនៅបណ្តាទីកន្លែងជាច្រើននៅក្នុងកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅតាមមូលដ្ឋានសហគមន៍នៅក្នុងប្រទេសកម្ពុជា។ ផ្ទុយទៅវិញខ្សែវីដេអូនេះ អង្គការអុកស្វាមបានកែសំរួលនិងផលិតចេញពីលំនាំដើមរបស់កាកបាទក្រហមវៀតណាម (VNRC)។ ដោយសហការជាមួយអង្គការអុកស្វាម, ច្បាប់ចំលង (ឌីសថតចំលង) ជាច្រើននៃខ្សែវីដេអូនេះបានចែកទៅអោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDMs) និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (DCDMs) នៅក្នុងខេត្តគោលដៅទាំងពីរ ដោយមានកិច្ចព្រមព្រៀងថានឹងធ្វើការចាក់បញ្ចាំងខ្សែវីដេអូទាំងនេះជូនដល់សហគមន៍ និងទីប្រជុំជន ហើយធ្វើការចែកចាយបន្តដល់ផ្ទះ រឺកន្លែងណាដែលមានម៉ាស៊ីនវីឡាលចាក់កាសែតខ្សែវីដេអូនេះ។

- ***ការសំដែងសិល្បៈនៅតាមសហគមន៍***

ការសំដែងសិល្បៈ និងចំរៀងប្រជាប្រិយប្រពៃណីដែលជាប្រព័ន្ធផ្សព្វផ្សាយពតិមានកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់បានបង្ហាញថា វាពិតជាមានការចាប់អារម្មណ៍និងជាទីពេញនិយមរបស់សហគមន៍មែន។ ក្រុមសំដែង និងតារាចំរៀងគឺជាក្រុមដែលមានស្នាដៃសំដែងល្អ និងមានប្រជាប្រិយនៅក្នុងប្រទេសកម្ពុជា។ ការសំដែងនេះរៀបចំឡើងនៅ

ពេលណាដែលមានបុណ្យទាននិងពិធីពិសេសផ្សេងៗតែប៉ុណ្ណោះ។ ការបង្កើតអោយមានប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី វប្បធម៌ និងការកំសាន្តបែបនេះ គឺបានរៀបចំដោយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តដែលមានបទពិសោធន៍នៅក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបនេះ នៅក្នុងការផ្សព្វផ្សាយសារដែលទាក់ទងនឹងបញ្ហាអេដស៍ (HIV/AIDS) និងបញ្ហាស្ត្រី ដូចជាអំពើហិង្សាជាដើម។

ដោយមានការចូលរួមពីធនធានមនុស្សនិងអ្នកជំនាញនៅតាមមូលដ្ឋាន អង្គការ ADPC បានយល់ព្រមហើយបានត្រឹមតែផ្តល់ជំនួយគាំទ្របច្ចេកទេស និង លើកទឹកចិត្តដល់ដៃគូអនុវត្តន៍ដែលមានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរបស់ខេត្តគោលដៅទាំងពីរតែប៉ុណ្ណោះ។ មន្ត្រីថ្នាក់ខេត្តមានតួនាទីគិតគូរលើការបង្កើត និង រៀបចំការសំដែងនៅតាមសហគមន៍ក្នុងការធ្វើយ៉ាងណាអោយការបញ្ជូនសារពីវិធានការកាត់បន្ថយគ្រោះទឹកជំនន់នេះ មានប្រសិទ្ធភាពខ្ពស់។

ការសំដែងនៅលើឆាកជាមធ្យោបាយចំណាយតិចតែមួយគត់ដែលអាចទាក់ទាញប្រជាពលរដ្ឋបានច្រើន និងអ្នកទស្សនាទាំងប្រុសស្រីគ្រប់អាយុ អាចទទួលដឹងឮទាំងអស់គ្នា។ ការសំដែងទាំងអស់មានចំនួន២២លើកដែលមានទស្សនិកជនចំនួនប្រហែល ៧.៣២៨ នាក់ហើយជាមធ្យមមានអ្នកចូលទស្សនាជាង ៦០០ នាក់ក្នុងមួយៗលើក។ ដូចនេះវាអាចបង្ហាញអោយឃើញថា ការផ្សព្វផ្សាយ ការយល់ដឹងពីគ្រោះទឹកជំនន់នេះ នឹងកាន់តែមានប្រសិទ្ធភាព។



*ចំរៀងចាប៉ីដងវែងសំដែងនៅតាមសហគមន៍ ត្រូវបានគេប្រើប្រាស់ជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាព សំរាប់បង្កើនការយល់ដឹងជាសាធារណៈស្តីពីការកាត់បន្ថយគ្រោះភ័យដោយទឹកជំនន់។*

កត្តាមួយទៀតដែលធ្វើអោយមានភាពជោគជ័យនោះគឺដោយសារការរៀបចំដ៏ល្អនិងអ្នកសំដែងមានសមត្ថភាពខ្ពស់។ ទាំងនេះដោយសារបទពិសោធន៍របស់មន្ទីរវិចិតត្រសិល្បៈ និងវប្បធម៌ខេត្ត ដែលរួមសហការពីសាកលវិទ្យាល័យភូមិន្ទវិចត្រសិល្បៈនៅក្នុងការរៀបចំជាសាច់រឿង ដែលសមស្របទៅនឹងសហគមន៍ជនបទ នៃយុទ្ធនាការសំដែងនេះ។ អ្នកសំដែងមួយចំនួននៃក្រុមសិល្បៈនៅក្នុងខេត្តព្រៃវែងនេះ ក៏បានរៀបចំនូវការសំដែងដ៏ល្អៗនៅក្នុងប្រទេសកម្ពុជាដែលពួកគេភាគច្រើនធ្លាប់បានទទួលពានរង្វាន់ថ្នាក់ជាតិផងដែរ។

> លោក
> ពុទ្ធ សាវ៉ាត
> អនុប្រធានមន្ទីរវប្បធម៌
> និងវិចិតត្រសិល្បៈ ខេត្តព្រៃវែង បានមាន
> ប្រសាសន៍ថា : "អ្នកដែលសំដែងសិល្បៈទាំងនេះ
> ភាគច្រើនជាអ្នកដែលរស់នៅតាម
> តំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ ដូច្នេះ
> ហើយពួកគេមានការយល់ដឹង និងអោយតំលៃខ្លាំង
> ណាស់ទៅលើការសំដែងនេះ ហើយពួកគេ
> ជាអ្នកដែលមានជំនាញក្នុងការសំដែងនេះ
> ដែលធ្វើអោយការចែករំលែកសារ
> វិធានការការពារទឹកជំនន់មាន
> ប្រសិទ្ធភាពខ្ពស់"។

ដើម្បីអោយការផ្ទេរសារនៃការយល់ដឹងជាសាធារណៈនេះមានប្រសិទ្ធភាពខ្ពស់ សំនួរចំលើយ និងល្បែងកំសាន្តក៏បានរៀបចំឡើងនៅចុងបញ្ចប់នៃការសំដែងនេះផងដែរ ដោយផ្តល់ជារង្វាន់ចំពោះអ្នកដែលអាចឆ្លើយទៅនឹងសំនួរដែលទាក់ទងនឹងវិធានការការពារគ្រោះទឹកជំនន់។

ជោគជ័យជាក់ស្តែងនៃការសំដែងនេះ បានធ្វើអោយមន្ទីរពត៌មានខេត្តព្រៃវែង បានថតនូវការសំដែងនេះ ជាខ្សែវីដេអូ ហើយរក្សាទុកក្នុងថាសកាសែត (ឌីស) ដូចនេះពួកគេអាចចាក់មើលម្តងហើយម្តងទៀតនៅគ្រប់ពេល និងតាមកន្លែងដទៃទៀតបាន។ ពត៌មានដែលក្រុមសិល្បៈផ្សព្វផ្សាយនេះក៏បានទាក់ទាញការចាប់អារម្មណ៍ពីស្ថានីយ៍ទូរទស្សន៍មួយនៅក្នុងប្រទេសកម្ពុជា គឺទូរទស្សន៍បាយ័ន ដែលបានអញ្ជើញក្រុមសិល្បៈនេះទៅសំដែងនៅក្នុងកម្មវិធីរបស់ទូរទស្សន៍នេះ ដែលមានចំណងជើងថា "មរតកវប្បធម៌កម្ពុជា"។ នៅក្នុងខេត្តព្រៃវែង សារកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ក៏ត្រូវបានបញ្ជូនទៅដល់សាធារណៈជនទូទៅតាមរយៈតន្ត្រីចំរៀងប្រពៃណីខ្លីៗ ដែលធ្វើការកែប្រែបទកាព្យខ្លះៗដើម្បីបញ្ជូនសារយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ផងដែរ។

### សាច់រឿងសំដែង

*រឿងនេះនិយាយពីគ្រួសារមួយដែលរស់នៅភូមិដែលងាយរងគ្រោះដោយទឹកជំនន់។ការលំបាកដែលគ្រួសារបានជួបប្រទះនេះ បានធ្វើអោយឪពុកនិងកូនបានសំរេចចិត្តចាកចេញទៅរកការងារធ្វើនៅក្រុងភ្នំពេញ។ ឪពុកបានធ្វើការងារជាកម្មករសំណង់ហើយកូនស្រីធ្វើជាកម្មករកាត់ដេរនៅក្នុងរោងចក្រ។ ចំណែកឯម្តាយរស់នៅក្នុងភូមិតែងតែជួបការលំបាកក្នុងការដោះស្រាយព្រោះគាត់ត្រូវថែរក្សាកូនជាច្រើនដោយខ្លួនគាត់។ ដូចនេះគាត់បានទៅសុំយោបល់ពីអាជ្ញាធរភូមិបន្ទាប់មកពួកគាត់បានផ្តល់យោបល់ដ៏មានប្រយោជន៍ល្អៗ លើវិធានការត្រៀមបង្ការ ការឆ្លើយតប និងការស្តារឡើងវិញនៃគ្រោះទឹកជំនន់។ឪពុកនិងកូនមានការលំបាកជាខ្លាំងក្នុងការរស់នៅក្រុងភ្នំពេញ បន្ទាប់មកក៏សំរេចចិត្តត្រឡប់មករស់នៅជាមួយគ្រួសារនៅឯស្រុកវិញ ។ ឥឡូវគ្រួសារនេះ អាចដោះស្រាយនិងរស់នៅជាមួយនឹងគ្រោះទឹកជំនន់បានយ៉ាងល្អប្រសើរ ។*

- ***វគ្គបណ្តុះបណ្តាលនៅតាមឃុំ***

វគ្គបណ្តុះបណ្តាលកសាងសមត្ថភាព ដែលរៀបចំដោយអង្គការ ADPC នៅពេលចាប់ផ្តើមគំរោងកម្មវិធី FEMS គឺជាយុទ្ធសាស្ត្រសំខាន់ដែលប្រើប្រាស់នៅក្នុងការបង្កើនការយល់ដឹងរបស់អាជ្ញាធរខេត្ត-ស្រុក លើគោលគំនិត និង គោលការណ៍កាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់។ បន្ទាប់មកមន្ត្រីថ្នាក់ខេត្ត និងស្រុកនេះ ត្រូវបានបណ្តុះបណ្តាលបន្ថែមដើម្បីអោយពួកគេអាចផ្ទេរចំណេះដឹងនិងជំនាញដែលពួកគេទទួលបាន ទៅអោយក្រុមប្រឹក្សាឃុំពិសេសសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (CCDM) តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍ដល់ឃុំគោលដៅ។ ក្រុមដែលរៀបចំវគ្គបណ្តុះបណ្តាលឃុំនេះរួមមាន មន្ត្រីដែលមកពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយជាតិ (NCDM), គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត(PCDM), គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក(DCDM), មន្ទីរសុខាភិបាលខេត្ត, មន្ទីរធនធានទឹក(DHRW), កាកបាទក្រហមខេត្ត និង អង្គការ ADPC ។

## ២.២-ការបង្កើនការយល់ដឹងដល់ក្រុមដែលងាយរងគ្រោះ

ក្រៅពីការបង្កើនការយល់ដឹងរបស់មន្ត្រីនៅតាមមូលដ្ឋានក្រុមដែលងាយរងគ្រោះជាងគេចំនួនពីរក្រុមនៅក្នុងសហគមន៍ដែលមានផលប៉ះពាល់ដោយគ្រោះទឹកជំនន់ក៏ត្រូវបានកំណត់សំរាប់ធ្វើយុទ្ធនាការយល់ដឹងមួយ ដល់ពួកគេផងដែរនោះគឺសិស្សសាលា និងស្ត្រីជាមេគ្រួសារ។ ការកំនត់នេះកើតឡើងពីការពិភាក្សារបស់អាជ្ញាធរខេត្តនិងស្រុក

ក្នុងការជ្រើសរើសគោលគំនិតសាកល្បងនៅក្នុងកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ដែលបង្កើតនៅក្រោមដំណើរការរៀបចំផែនការផ្សេងគ្នាមួយនៅក្រោមគំរោងកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ។

**ឯកសារពត៌មានគ្រោះទឹកជំនន់**

*ឯកសារពត៌មានគ្រោះទឹកជំនន់ត្រូវបានរៀបចំយ៉ាងពិសេស សំរាប់ផ្តល់ទៅអោយគ្រូបង្រៀន និងអ្នកអប់រំ ជាមួយនឹងពត៌មាន និងសំភារៈសំរាប់ផ្សព្វផ្សាយសារស្តីពីវិធានការការពារគ្រោះទឹកជំនន់ដល់សិស្សសាលា ។ ឯកសារពត៌មាននេះរួមមាន ៈ*

- *កូនសៀវភៅគ្រោះទឹកជំនន់ ដែលនិយាយ "ពីវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់*
- *កូនសៀវភៅស្តីពីការផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់នៅតាមសហគមន៍*
- *ពត៌មាន "ការរស់នៅជាមួយគ្រោះទឹកជំនន់" ដែលរួមមានកាសែត វីដេអូ និងកូនសៀវភៅផ្សេងៗ*
- *កូនសៀវភៅស្តីពី "បញ្ហាសុខភាព ពេលទឹកជំនន់"*

- ***កូនសិស្សសាលា***

ការបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ដល់សិស្សសាលាបានអនុវត្តន៏តាមរយៈវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀននៅតាមមូលដ្ឋាន ។ នេះបង្ហាញអោយឃើញថាមានជោគជ័យយ៉ាងច្រើន ព្រោះគ្រូបង្រៀនគឺគួរអោយគោរពណាស់ពីសហគមន៏នៅតាមមូលដ្ឋាន ។ ដំណើរការបង្កើនការយល់ដឹងនេះចាប់ផ្តើមផ្សព្វផ្សាយក្នុងចំណោមគ្រូបង្រៀនរបស់គេផ្ទាល់ ។ ក្នុងលក្ខណៈនេះពួកគេអាចមានការប៉ិនប្រសប់ទាំងខាងផ្ទេរចំណេះដឹង និងអាកប្បកិរិយា មិនថាដល់សិស្សសាលាទេ ប៉ុន្តែថែមទាំងដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៏ផងដែរ ។ ឯកសារពត៌មានល្អៗនិងត្រឹមត្រូវស្តីពីគ្រោះទឹកជំនន់ត្រូវបានរៀបចំផ្តល់អោយពួកគេជាមួយនឹងឯកសារយោង ដែលពួកគេអាចប្រើប្រាស់បានរយៈពេលយូរអង្វែង ។

សិក្ខាសាលាស្តីពី "វគ្គបណ្តុះបណ្តាលសំរាប់គ្រូនិងអ្នកអប់រំ" ត្រូវបានរៀបចំនៅក្នុងស្រុកគោលដៅទាំងបួននៃខេត្តព្រៃវែង និងខេត្តកណ្តាល ដែលមានសិក្ខាកាមចំនួន ៧៦ នាក់ រួមមានមន្ត្រីខេត្តស្រុកនៃមន្ទីរអប់រំយុវជន និងកីឡា, នាយកសាលា និងគ្រូបច្ចេកទេស (អ្នកដែលទទួលខុសត្រូវរៀបចំកម្មវិធីសិក្សា) ដែលមកពីសាលា នៅតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់ខ្លាំង ។

នៅសិក្ខាសាលានាយកសាលានិងគ្រូបច្ចេកទេសបានរៀបចំផែនការសកម្មភាពសំរាប់ផ្សព្វផ្សាយបន្តទៀតនៅក្នុងសហគមន៏របស់ពួកគេពិសេសនៅក្នុងសាលា ។ អង្គការស្រែខ្មែរដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកជាអ្នកផ្តល់ជំនួយបច្ចេកទេសគាំទ្រនៅក្នុងការផ្សព្វផ្សាយនេះទៅដល់គ្រូនៅក្នុងសាលាគោលដៅដែលរួមមានការរៀបចំកិច្ចតែងការជាដើម ។

- ***ស្ត្រីជាមេគ្រួសារ***

យុទ្ធនាការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ដល់ស្ត្រីជាមេគ្រួសារបានរៀបចំជាជំហានដំបូងនៃកិច្ចការដ៏ធំ និងយូរអង្វែងរបស់គំរោង FEMS ដើម្បីបញ្ចូលបញ្ហាយេនឌ័រ ទៅក្នុងកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និងស្រុក ។ ស្ត្រីជាមេគ្រួសារត្រូវបានកំនត់ ថាជាអ្នកដែលងាយរងគ្រោះបំផុតមួយនៃចំនួនប្រជាជននៅសហគមន៏ក្នុងតំបន់គោលដៅ ។ មន្ត្រីថ្នាក់ខេត្តនិងស្រុករបស់មន្ទីរកិច្ចការនារីដើរតួនាទីជាអ្នកដឹកនាំនៅក្នុងបញ្ហាទាំងអស់ដែលទាក់ទងនឹងយេនឌ័រ ជាមួយនឹងអង្គការ ADPC និង អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ ដែលមានឈ្មោះថាអង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា (PCC) ដោយផ្តល់ជាជំនួយគាំទ្របច្ចេកទេស ។ អង្គការ PCC ត្រូវបានជ្រើសរើសជាដៃគូអនុវត្តន៏ ដោយសារចំនេះដឹង និង ជំនាញរបស់អង្គការនេះ ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ (Gender) នៅតាមមូលដ្ឋាន ។

អ្នកស្រី
សៅ សាវ៉ាន
អនុប្រធានមន្ទីរកិច្ចការនារីខេត្ត ព្រៃវែង
បានមានប្រសាសន៏ថា ៈ "កិច្ចប្រជុំជាច្រើនសំរាប់ស្ត្រី ជាមេគ្រួសារមានសិក្ខាកាមចូលរួមយ៉ាងច្រើន ពិសេសបើប្រៀបធៀបនឹងការចូលរួមរបស់ពួកគេនៅក្នុងកិច្ចប្រជុំនៅតាមភូមិ ដែលពួកគេពុំសូវនិយាយអ្វីទេ...ប៉ុន្តែនៅក្នុងកិច្ចប្រជុំជាក្រុមតូចនេះ ពួកគេ មានការនិយាយពិភាក្សាគ្នា និង បញ្ចេញយោបល់បានច្រើនណាស់" ។

នៅថ្នាក់សហគមន៏ជនបង្គោលនារីរបស់ក្រុមប្រឹក្សាឃុំ បានដើរតួដឹកនាំ និង ធ្វើការជាមួយអ្នកស្ម័គ្រចិត្តភូមិនៅក្នុងការរៀបចំវគ្គផ្សព្វផ្សាយពត៌មានជាមួយស្ត្រី ជាមេគ្រួសារ ។ ការផ្សព្វផ្សាយនេះបានកំណត់ធ្វើនៅភូមិ ចំនួន ២ ទៅ ៣ នៅក្នុងឃុំនីមួយៗ ។

ការរៀបចំនៃវគ្គផ្សព្វផ្សាយពត៌មាន និងការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ទាំងនេះត្រូវបានគាំទ្រដោយពត៌មានជាច្រើនដែលបានរៀបចំចេញពីករណីសិក្សាដែលមានស្រាប់ស្តីពីបញ្ហាយេនឌ័រ, ឯកសារស្រាវជ្រាវ, និងលទ្ធផលដែលបានមកពីសិក្ខាសាលាជាក់ស្តែងនៅថ្នាក់ខេត្ត-ស្រុកដែលរៀបចំដើម្បីកំនត់និងដោះស្រាយបញ្ហានៃភាពងាយរងគ្រោះ របស់ស្ត្រីជាមេគ្រួសារទៅនឹងគ្រោះទឹកជំនន់ ។

បន្ទាប់ពីការរៀបចំនៃវគ្គបង្កើនការយល់ដឹងនេះហើយអង្គការPCC បានសំរបសំរួលលើការបង្កើតផែនការសកម្មភាពសំរាប់ជនបង្គោលនារីរបស់ក្រុមប្រឹក្សាឃុំ ដែលវគ្គនេះរៀបចំជាមួយនឹងស្ត្រីជាមេគ្រួសារនៅក្នុងភូមិដទៃទៀតនៃឃុំគោលដៅ ។ សៀវភៅស្តីពីផលប៉ះពាល់នៃគ្រោះទឹកជំនន់លើស្ត្រីជាមេគ្រួសារ ដែលនឹងប្រើប្រាស់នៅក្នុងការរៀបចំវគ្គបង្កើនការយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់នៅពេលអនាគតគឺត្រូវបានរៀបចំរួចរាល់ហើយ ។



## ៣_មេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៍

- ការរៀបចំនិងការបង្កើតយុទ្ធនាការយល់ដឹងជាសាធារណៈ មានការនឿយហត់បន្តិចនិងប្រើប្រាស់ពេលវេលាប៉ុន្តែបើកាលណាយើងបានបង្កើតហើយនោះវានឹងមាន អាយុកាលយូរ និង អាចប្រើប្រាស់បានម្តងហើយម្តងទៀត ។
- នៅពេលដែលដៃគូអនុវត្តន៏តាមមូលដ្ឋានត្រូវបានលើកទឹកចិត្ត ហើយទទួលយកភាពម្ចាស់ការលើគោលគំនិតនេះហើយនោះសមត្ថភាព និង ធនធាននៅមូលដ្ឋាន ដែលមិនទាន់មាន នឹងមានឡើងជាមិនខានឡើយ ។
- យុទ្ធនាការយល់ដឹងជាសាធារណៈនេះ ត្រូវតែរៀបចំឡើង និងផ្សព្វផ្សាយ ដោយផ្អែកលើទំនៀមទំលាប់របស់សង្គម និងវប្បធម៏ដែលមានស្រាប់នៅតាមមូលដ្ឋាន នោះសារយល់ដឹងជាសាធារណៈនេះនឹងទទួលបានការយល់ដឹងច្រើន និងមានប្រសិទ្ធភាព ។
- យើងមិនចាំបាច់កែប្រែលំនាំដើមទេ មានន័យថា សំភារៈ និងឯកសារយល់ដឹងមានស្រាប់ដែលបានបង្កើតឡើងដោយអង្គការដទៃទៀត អាចធ្វើការកែសំរួល ឱ្យត្រូវទៅនឹងលក្ខខ័ណ្ឌរបស់មូលដ្ឋាន ដែលធ្វើអោយជំហាននៃការស្រាវជ្រាវ និងការរៀបចំមានរយៈពេលខ្លី ។
- ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈគឺជាវិធីសាស្រ្តដ៏ល្អបំផុតដែលនាំមកនូវគំនិតច្នៃប្រឌិត និងកំនែប្រែថ្មីៗ ។ គំនិត និងវិធីសាស្រ្ត ដែលមានប្រសិទ្ធភាពបំផុត គឺបានមកពីអង្គការ និងក្រុមដែលមានការងារទាក់ទងនឹងសិល្បៈ វប្បធម៏ ប្រព័ន្ធផ្សព្វផ្សាយ និងកិច្ចការនារី ។ ការប្រើប្រាស់នៃបណ្តាញ និងប្រព័ន្ធផ្សព្វផ្សាយទំនើបថ្មីៗនៃការបញ្ជូនពតិមានគឺជាកត្តាដ៏សំខាន់មួយដែលធ្វើអោយការយល់ដឹងរបស់សហគមន៏មានកំរិតខ្ពស់ ។
- ប្រសិទ្ធភាពនៃការចំណាយ និងភាពងាយស្រួលក្នុងការអនុវត្តន៏នូវយុទ្ធនាការបន្ត គឺជាលក្ខណៈសំខាន់ពីរដ៏មានប្រសិទ្ធភាពបំផុតនៃវិធីសាស្រ្តយល់ដឹងដែលបានអនុវត្តន៏នៅក្នុងគំរោងទឹកជំនន់នេះគឺ ការសំដែងសិល្បៈនៅតាមសហគមន៏ និងការបញ្ជូលកម្មវិធីកាត់បន្ថយគ្រោះទឹកជំនន់ទៅក្នុងកម្មវិធីសិក្សាសាលា ។
- ការកសាងសមត្ថភាពមូលដ្ឋាន លើការអនុវត្តន៏យុទ្ធនាការជាសាធារណៈនៅពេលអនាគត អាចធ្វើអោយមានប្រសិទ្ធភាពច្រើន នៅពេលដែលដៃគូអនុវត្តន៏មូលដ្ឋានធ្វើសកម្មភាពផ្សព្វផ្សាយបន្តនៃការយល់ដឹងនេះដោយខ្លួនពួកគេផ្ទាល់ ។
- ក្រុមជនដែលងាយរងគ្រោះបំផុតនៅក្នុងសហគមន៏ រួមមានស្រ្តី,មនុស្សចាស់, កុមារ...ជាដើម នឹងមានលក្ខណៈប្រសើរ ប្រសិនបើយុទ្ធនាការយល់ដឹងមួយនេះបានរៀបចំឱ្យត្រូវទៅនឹងការយល់ឃើញ និងទស្សនវិស័យរបស់ពួកគេ ។

## ៤_ជំហានអនុវត្តន៏បន្ទាប់

កម្មវិធីយុទ្ធនាការយល់ដឹងជាសាធារណៈដែលបានរៀបចំដោយ ដៃគូអនុវត្តន៏នៅមូលដ្ឋានបានទទួលជោគជ័យគួរជាទីពេញចិត្តនិងមានប្រសិទ្ធភាព ប៉ុន្តែការវាយតំលៃប៉ាន់ប្រមាណមិនទាន់បានធ្វើនៅឡើយទេ ។ ការវាយតំលៃនេះជាដំណើរការសំខាន់ចំពោះសកម្មភាពយុទ្ធនាការយល់ដឹងជាសាធារណៈ និងសមត្ថភាពយល់ដឹងពីគ្រោះភ័យនៃគ្រោះទឹកជំនន់ ។ ប្រព័ន្ធផ្សព្វផ្សាយជាច្រើនដែលបានប្រើរួមមាន ផ្ទាំងរូបភាព កូនសៀវភៅ និងខ្សែវីដេអូជាដើម បានធ្វើអោយយុទ្ធនាការផ្សព្វផ្សាយមានភាពជោគជ័យ ប៉ុន្តែវាមានការពិបាកណាស់ក្នុងការកំនត់ថា ប្រព័ន្ធផ្សព្វផ្សាយណាមួយមានប្រសិទ្ធភាពខ្លាំងរឺតិចនោះទេ ។ បើគ្មានការវាយតំលៃមួយនោះទេ ការរីកចំរើនក៏មិនអាចកំនត់បានច្បាស់នោះទេ ហើយទំហំនៃមេរៀន និងបទពិសោធន៏ក៏មិនអាចវាស់វែងដឹងផងដែរ ។

ការរៀបចំការស្ទង់មតិខ្លីៗ ដើម្បីកំនត់កំរិតនៃការយល់ដឹង, អាកប្បកិរិយា និងការអនុវត្តន៏(KAP) របស់ប្រជាពលរដ្ឋនៅតំបន់ គោលដៅ មុនពេលរៀបចំយុទ្ធនាការយល់ដឹងមួយ នឹងផ្តល់ពតិមានដ៏មានប្រយោជន៏នៅក្នុងការកំនត់ពីសារ និង បណ្តាញបញ្ជូនពតិមាន អ្វីដែលសមស្របបំផុតនោះ ។ ការស្ទង់មតិដែលរៀបចំបន្ទាប់ពីយុទ្ធនាការអាចផ្តល់នូវវិធានការ និងពតិមានល្អៗលើប្រសិទ្ធភាព នៃប្រភេទប្រព័ន្ធផ្សព្វផ្សាយនានាដែលបានប្រើ និងប្រសិទ្ធភាពនៃយុទ្ធនាការទាំងមូល ។

### សេចក្តីថ្លែងអំណរគុណ

សហគមន៏មានសុវត្ថិភាព សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីអ្នកទាំងអស់ដូចខាងក្រោមក្នុងការរៀបចំចងក្រងករណីសិក្សានេះ :

លោក Aloysisus Rego ប្រធានក្រុម ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ

លោក Thanongdeth Insisiengmay ប្រធានគ្រប់គ្រងកម្មវិធី ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ADPC, ប្រទេសកម្ពុជា

លោក Aslam Perwaiz ប្រធានគ្រប់គ្រងគំរោង, ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ

លោក ជុំ វុទ្ធី , ប្រធានគ្រប់គ្រងគំរោងថ្នាក់ជាតិ, ADPC, ប្រទេសកម្ពុជា

លោក អុល សែន, អ្នកសំរបសំរួលកម្មវិធី, ADPC, ប្រទេសកម្ពុជា

លោក ប៊ី ច័ន្ទតុលា, ជំនួយការគំរោង, ADPC, ប្រទេសកម្ពុជា

លោក Jerome Casals, អ្នកនិពន្ធ

លោក លឹម តារា, អ្នករចនាអត្ថបទ

សហគមន៍មានសុវត្ថិភាព ជាឈុតនៃករណីសិក្សា ដែលបានដកស្រង់យកអនុវត្តន៍ល្អៗមកបង្ហាញទាក់ទងនឹងការត្រៀមបង្ការ និងកាត់បន្ថយ គ្រោះមហន្តរាយ ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលនិង អង្គការក្រៅរដ្ឋាភិបាល សំដៅកាត់បន្ថយភាពងាយរងគ្រោះ និង គ្រោះភ័យនៃគ្រោះមហន្តរាយរបស់សហគមន៍ ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ។

ករណីសិក្សានេះ មានទិសដៅផ្តល់ដល់អ្នកធ្វើការសំរេចចិត្ត អ្នកធ្វើផែនការអភិវឌ្ឍន៍ អ្នកអនុវត្តន៍ការងារគ្រប់គ្រងគ្រោះមហន្តរាយ អ្នកដឹកនាំសហគមន៍ និង អ្នកអប់រំនានានូវគំនិតច្នៃប្រឌិត ឧបករណ៍ យុទ្ធសាស្ត្រ និង ជំរើសគោលនយោបាយនានា ដែលបានដកស្រង់ពីបទពិសោធន៍ពិតប្រាកដ ការអនុវត្តន៍ល្អៗ និង មេរៀនល្អៗ ដែលទទួលបានពីតំបន់អាស៊ីប៉ាស៊ីហ្វិច ទាក់ទង នឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ព្រមទាំងកសាងអោយបាននូវភាពជួយខ្លួនឯងរបស់សហគមន៍ និង ធ្វើអោយមានសង្គម ដែលមានការត្រៀមបង្ការគ្រោះមហន្តរាយបានល្អប្រសើរ ។

ក្នុងដំណាក់កាលទី១នេះ ករណីសិក្សាមួយចំនួនត្រូវបានរៀបចំក្រោមផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយ គ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ ។ ដូចនេះករណីសិក្សានេះបានផ្តោតសំខាន់តែទៅលើការគ្រប់គ្រងគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមតំបន់ភូមិសាស្ត្រនៃប្រទេស ជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលមានប្រទេស កម្ពុជា ឡាវ ថៃឡង់ដ៏ និងវៀតណាម ។ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍និង ការអនុវត្តន៍ល្អៗដែលទទួលបាន ពីបណ្តាប្រទេសដទៃទាក់ទងនឹងគ្រោះ មហន្តរាយធម្មជាតិនឹងត្រូវដាក់បញ្ចូលបន្ថែមនៅពេលក្រោយៗទៀត ។

គោលបំណងនៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មាធិការទន្លេមេគង្គ គឺដើម្បីការពារ និងកាត់បន្ថយទុក្ខវេទនារបស់ប្រជាជន និងការខូចខាតសេដ្ឋកិច្ច ដែលបណ្តាលមកពីគ្រោះទឹកជំនន់ និងថែរក្សាបរិស្ថាននៃទឹកជំនន់អោយនៅគង់វង្ស ។ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់មាន ៥ផ្នែកសំខាន់ៗដូចខាងក្រោម:

ផ្នែកទី ១ : បង្កើតមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់

ផ្នែកទី ២ : វិធានការណ៍បែបរចនាសម្ព័ន្ធ និងការទប់ស្កាត់គ្រោះទឹកជំនន់

ផ្នែកទី ៣ : ការសំរបសំរួលបញ្ហាគ្រោះទឹកជំនន់ឆ្លងដែន

ផ្នែកទី ៤ : ការពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់

ផ្នែកទី ៥ : ការគ្រប់គ្រងដី

ផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) នេះ ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គ ដោយជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងឧបត្ថម្ភថវិកាដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ) ដែលបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០០៤ ដល់ខែមេសា ឆ្នាំ២០០៨។ តំបន់គោលដៅរបស់គំរោងនេះមាននៅក្នុងប្រទេសកម្ពុជា និងវៀតណាម ដែលប្រទេសនីមួយៗយកខេត្ត២ និងស្រុក៤ ជាតំបន់គោលដៅ។ ដៃគូររបស់គំរោងនេះ មានគណៈកម្មាធិការជាតិទន្លេមេគង្គ, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរមូលដ្ឋានប្រចាំខេត្ត ស្រុក និងឃុំរបស់គេ, មន្ទីរ-ការិយាល័យពាក់ព័ន្ធ, ស្ថាប័នផ្សេងៗ, កាកបាទក្រហម, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ។ល។

ចាប់តាំងពីឆ្នាំ ២០០៤ មក គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) បានសំរេចសមិទ្ធិផលដូចខាងក្រោម:

១-កម្មវិធិត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងស្រុកនិងខេត្តគោលដៅត្រូវបានបង្កើត និងអនុវត្ត

២-សមត្ថភាពថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិត្រូវបានបង្កើនក្នុងការគាំទ្រទៅលើដំណើរការបង្កើត និងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ តាមរយៈការបណ្តុះបណ្តាលនៅកំរិតមូលដ្ឋាន ស្តីការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមសហគមន៍, ការប៉ាន់ប្រមាណការខូចខាតនិងសេចក្តីត្រូវការ, ការរុករកនិងសង្គ្រោះ, ការគ្រប់គ្រងគ្រោះអាសន្នដល់កុមារតូចៗ, ការបង្ហាត់ហែលទឹកដល់កុមារ ។ល ។ ហើយនិងការចូលរួមទៅក្នុងការអនុវត្តគំរោង ។

៣-ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈស្តីពីវិធានការសុវត្ថិភាពគ្រួសារថ្នាក់មូលដ្ឋានត្រូវបានបង្ហាញ រួមមានការផ្សព្វផ្សាយដល់គ្រូបង្រៀន និងកម្មវិធីសុវត្ថិភាពគ្រោះទឹកជំនន់នៅតាមសាលារៀន, ការកំណត់ពីតំរូវការចាំបាច់របស់ស្ត្រីមេគ្រួសារ, ការសំដែងសិល្បៈ, ចាប៉ីដងវែង, ការចែកផ្សព្វផ្សាយសៀវភៅទឹកជំនន់, ផ្ទាំងរូបភាព ជាដើម ។

៤-ការចែករំលែកបទពិសោធន៍ថ្នាក់មូលដ្ឋាន និងតំបន់ត្រូវបានរៀបចំឡើងតាមរយៈសិក្ខាសាលាជាតិ និងតំបន់ ព្រមទាំងធ្វើការបែងចែកឯកសារបទពិសោធន៍ល្អៗជាច្រើន ។

---

**សំរាប់ពត៌មានបន្ថែម អ្នកអានអាចទាក់ទងអាស័យដ្ឋានដូចខាងក្រោម**


អ្នកសំរបសំរួលកម្មវិធីគ្រប់ គ្រងនិងកាតបន្ថយគ្រោះទឹកជំនន់
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.mrcmekong.org

ប្រធានគ្រប់គ្រងកម្មវិធី, មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.adpc.net email : antonio@adpc.net


---

**ដៃគូរគំរោង**


លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC)
ប្រអប់សំបុត្រលេខ ៦១០១ អគារលេខ ១៨ បានស៊ីថានេនូវ ខ័ណ្ឌស៊ីកុតថាបុង
ក្រុងវៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ: (៨៥៦) ២១ ២៦៣ ២៦៣ ទូរសារ: (៨៥៦) ២១ ២៦៣ ២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org វ៉ិបសាយ: http://www.mrcmekong.org

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)
ផ្ទះលេខ ២៣ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ២១៨ ៧២៧ ទូរសារ: (៨៥៥) (២៣) ២១៨ ៥០៦
អ៊ីម៉ែល: cnmcs@cnmc.gov.kh វ៉ិបសាយ: http://www.camnet.com.kh/cnmcs

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)
ផ្លូវលេខ ៥១៦ សង្កាត់ទួលសង្កែ ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ/ ទូរសារ: (៨៥៥) (២៣) ៨៨២ ០៤៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល (PCDM)
ឃុំដើមមាន ស្រុកតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៤២៥៥៥៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង (PCDM)
ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៩៤៤ ៥៤៦

adpc

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)
SM Tower, ជាន់ ទី២៤, ៩៧៩/៦៩, Paholyothin, Samsen Nai, Phayathai,
ក្រុងបាងកក, ប្រទេសថៃ
ទូរស័ព្ទ: (៦៦) ២២ ៩៨ ០៦៨១ ដល់ ៩២
ទូរសារ: (៦៦) ២២ ៩៨ ០០១២ ដល់ ១៣
អ៊ីម៉ែល: adpc@adpc.net វ៉ិបសាយ: www.adpc.net



ឧបត្ថម្ភដោយ:

gtz Partner for the Future Worldwide
on behalf of:
Federal Ministry for Economic Cooperation and Development

ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាឡឺម៉ង់ (GTZ)